# របាំប្រជាប្រិយ



ឈ្មោះ **របាំនេសាទ**

សេចក្តីសង្ខេប ៖ របាំប្រពៃណីដ៏រស់រវើកនេះឆ្លុះបញ្ចាំងពីជីវិតប្រចាំថ្ងៃរបស់ កសិករ និងអ្នកនេសាទ។ របាំនេះត្រូវរាំជាមួយនឹងសម្ភារៈនេសាទដែលធ្វើពីឫស្សី ដូចជា អង្រុត ឈ្នៀង ទ្រូ និង លប។



ឈ្មោះ **របាំត្រោកប៉ៃលិន**

ប្រភព៖ ខេត្តប៉ៃលិន

សេចក្តីសង្ខេប៖ របាំនេះ មានប្រភពដើមពីជនជាតិភាគតិចកូឡាដែលរស់នៅក្នុងតំបន់មួយនៃខេត្តប៉ៃលិនដែលស្ថិតនៅភាគខាងលិចនៃប្រទេសកម្ពុជា។ របាំនេះមានទំនាក់ទំនងនឹងរឿងនិទានមួយរបស់អ្នកប៉ៃលិនដែលនិយាយអំពីក្ងោកមានបុណ្យមួយទៅទេសនាថ្វាយស្តេច។ របាំដ៏រស់រវើកនេះគឺមានគោលបំណងរំឭកដល់ក្ងោកមានបុណ្យនោះដែលជាតំណាងឲ្យសុភមង្គល។ របាំនេះយកតាមសត្វក្ងោក ដែលមានពណ៌ស្រស់ឆើតឆាយ និងឈុតនៃការចែចង់រវាងក្ងោកឈ្មោល និងក្ងោកញី។ គេនិយាយថារបាំនេះនាំមកនូវសុភមង្គល និងភាពរុងរឿងដល់អ្នកភូមិ។ ហេតុដូច្នេះហើយ ទើបរបាំនេះជាញឹកញាប់ត្រូវបានសម្តែងឡើងនៅកំឡុងពេលចូលឆ្នាំប្រពៃណីជាតិខ្មែរ និងពិធីបួងសួងសុំទឹកភ្លៀងនៅពេលដែលមានគ្រោះរាំងស្ងួត។



ឈ្មោះ **របាំបុកល្អក់**

សេចក្តីសង្ខេប៖ ជាទូទៅ របាំនេះច្រើនរាំនៅក្នុងពិធីមង្គលការ។ នាពេលនេះ មនុស្សស្រីខ្មែរដែលមានវ័យចំណាស់នៅតែប្រកាន់ខ្ជាប់នូវប្រពៃណីបុរាណនៃការធ្វើឲ្យធ្មេញខ្មៅភ្លឺរលោងដោយសារ ការទំពាស្លឹកម្លូរ និងស្លា។ ប្រពៃណីនេះនៅតែមានអនុវត្តនៅក្នុងតំបន់មួយចំនួន ក្នុងប្រទេសកម្ពុជារហូតមកដល់សព្វថ្ងៃនេះ។



ឈ្មោះ **របាំច្រូតស្រូវធំ**

សេចក្តីសង្ខេប៖ របាំនេះពណ៌នាអំពីសកម្មភាពធ្វើស្រែប្រចាំថ្ងៃរបស់អ្នកភូមិក្នុងការប្រមូលផលស្រូវនៅរដូវច្រូតកាត់។



ឈ្មោះ **របាំចាក់អង្រ្កង**

ប្រភព៖ ខេត្តសៀមរាប

សេចក្តីសង្ខេប៖ របាំនេះឆ្លុះបង្ហាញពីសកម្មភាពរបស់អ្នកភូមិ ក្នុងការប្រមូលពងអង្រ្កងមកទុកធ្វើជាជ្រក់ដែលជា អាហារដ៏ឆ្ងាញ់ពិសាមួយបែប។ អ្នករាំរបាំនេះត្រូវរាំជាមួយឈើវែងមួយ ដែលមានកន្រ្តកនៅខាងចុង ដើម្បីប្រើប្រាស់ក្នុងការប្រមូលពងអង្រ្កង។



ឈ្មោះ **របាំត្រុដិនាងម៉េវ**

ប្រភព៖ ខេត្តសៀមរាប

សេចក្តីសង្ខេប៖ របាំដ៏ពេញនិយមមួយនេះត្រូវបានសម្តែងឡើងក្នុងគោលបំណងដើម្បីបួងសួងដល់ទេវតាឲ្យប្រទានទឹកភ្លៀងនៅក្នុងកំឡុងពេលអាកាសធាតុហួតហែងគ្មានភ្លៀងជាយូរថ្ងៃ។ របាំនេះអាចមានរយៈពេលវែងអាស្រ័យលើរយៈពេលរាំងហួត និងទំហំនៃតំបន់ដែលគ្មានភ្លៀងនោះ ព្រោះអ្នករាំអាចដើរពីភូមិមួយទៅភូមិមួយទៀត។ បច្ចុប្បន្នរបាំនេះច្រើនធ្វើឡើងនៅក្នុងកំឡុងពេលបុណ្យចូលឆ្នាំប្រពៃណីខ្មែរព្រោះគេមានជំនឿថា ការធ្វើបែបនេះនឹងដេញឧបទ្រពចង្រៃនៅក្នុងឆ្នាំចាស់ ទទួលបានភាពរុងរឿង និងសុភមង្គលសម្រាប់សហគមន៍ និងប្រជាជនក្នុងប្រទេសទាំងមូល។



ឈ្មោះ **របាំគោះត្រឡោក**

ប្រភព៖ ខេត្តស្វាយរៀង

សេចក្តីសង្ខេប៖ របាំដ៏មានប្រជាប្រិយភាពមួយនេះត្រូវបានកែច្នៃបន្តពីល្បែងគោះត្រឡោកដែលពីមុនគេលេងនៅក្នុងពិធីមង្គលការ។ ប្រជាជនកម្ពុជាភាគច្រើន ស្រលាញ់ចូលចិត្តរបាំនេះណាស់ ដោយសារតែរបាំនេះមានចង្វាក់រន្ធំ និងភាពស្រុះគ្នានៃសម្រែក និងការគោះត្រឡោក។ ទាំងនេះបង្ហាញពីភាពសប្បាយរីករាយ និងសុភមង្គលក្នុងជីវិត។



ឈ្មោះ **របាំបេះក្រវ៉ាញ**

ប្រភព៖ ខេត្តពោធិ៍សាត់

សេចក្តីសង្ខេប ៖ របាំប្រជាប្រិយនេះមានប្រភព ដើមពីជនជាតិភាគតិចព័រដែលរស់នៅក្នុងស្រុកក្រវ៉ាញ ខេត្តពោធិ៍សាត់។ របាំនេះពណ៌នាពីប្រពៃណីបុណ្យសាសនាមួយរបស់អ្នកភូមិជនជាតិព័រ មុនពេលពួកគេចេញដំណើរទៅប្រមូលផលិតផលពិសេសៗពីក្នុងព្រៃ។



ឈ្មោះ **របាំឆៃយ៉ាំ**

សេចក្តីសង្ខេប៖ របាំឆៃយ៉ាំត្រូវបានគេស្គាល់ថា ជារបាំប្រពៃណីដែលសម្តែង មានលក្ខណៈ វាយស្គរ និងភាពកំប្លែង សូម្បីតែអ្នករាំក៏មានភាពញញឹមកម្ញក់ ផងដែរ។ ពេលខ្លះអ្នករាំអាចពាក់មុខ ឬគូរមុខ តាមបែបកំប្លែង។ ម្យ៉ាងទៀត របាំនេះក៏មានការស្រែកប្រកបដោយភាពច្នៃប្រឌិត និងចម្រៀងឆ្លើយឆ្លងដ៏ពិរោះព្រមជាមួយនឹងសម្លេង ទះដៃ និងឆាប។ របាំនេះច្រើនសម្តែងនៅក្នុងពិធីបុណ្យព្រះពុទ្ធ សាសនាដូចជា កឋិនទាន បុណ្យផ្កាបុណ្យបំបួសនាគ ជាដើម។ ដោយសារតែការជួយធ្វើឲ្យបរិយាកាសកាន់តែសប្បាយរីករាយ របាំ ប្រជាប្រិយនេះគឺពេញនិយមទាំងនៅក្នុងទីក្រុង និងជនបទនាពេល បច្ចុប្បន្ននេះ។



ឈ្មោះ **របាំត្រុដិ**

ប្រភព៖ ខេត្តសៀមរាប និងបាត់ដំបង

សេចក្តីសង្ខេប ៖ របាំនេះច្រើនត្រូវបានសម្តែងឡើងនៅក្នុងអំឡុងបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ដើម្បីដេញឧបទ្រព ចង្រៃ និងបួងសួងឲ្យមានទឹកភ្លៀងគ្រប់គ្រាន់សម្រាប់ឆ្នាំថ្មី។ បច្ចុប្បន្ន របាំនេះ ក៏នៅតែមានប្រជាប្រិយភាព និងពេញនិយមក្នុងបណ្តាប្រជាជនខ្មែរយើងផងដែរ។



ឈ្មោះ **របាំច្រូតស្រូវ**

សេចក្តីសង្ខេប៖ របាំនេះពណ៌នាអំពីសកម្មភាពដ៏រស់រវើក និងសប្បាយរីករាយរបស់ប្រជាកសិករខ្មែរក្នុងការប្រមូលទិន្នផលស្រូវនារដូវច្រូតកាត់។